# ការបន្តការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

*(សេចក្តីសម្រេចលេខ ៥៤ សសរ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាល)*

## រយៈពេលនៃការបន្តការបិទខ្ទប់

ការបន្តការបិទខ្ទប់នេះមានរយៈពេល **៧ ថ្ងៃ** រហូតដល់ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២១

*រយៈពេលបិទខ្ទប់នេះ អាចត្រូវបានបន្តបន្ថែមទៀត អាស្រ័យលើការចូលរួមអនុវត្តរបស់ប្រជាពលរដ្ឋ និងស្ថានភាពវិវត្តន៍នៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។*

## ការបែងចែកភូមិសាស្ត្របិទខ្ទប់ជា "តំបន់ក្រហម", "តំបន់លឿងទុំ" និង "តំបន់លឿង"

- **"តំបន់ក្រហម"** សំដៅដល់ភូមិសាស្ត្រដែលមានការឆ្លងរាលដាល "ធ្ងន់ធ្ងរ" នៃជំងឺកូវីដ-១៩ ក្នុងសហគមន៍។
- **"តំបន់លឿងទុំ"** សំដៅដល់ភូមិសាស្ត្រដែលមានការឆ្លងរាលដាល "កម្រិតមធ្យម" នៃជំងឺកូវីដ-១៩ ក្នុងសហគមន៍។
- **"តំបន់លឿង"** សំដៅដល់ភូមិសាស្ត្រដែលមានការឆ្លងរាលដាល "កម្រិតស្រាល" នៃជំងឺកូវីដ-១៩ ក្នុងសហគមន៍។

*រដ្ឋបាលរាជធានីភ្នំពេញ និងរដ្ឋបាលខេត្តកណ្តាល នឹងចេញសេចក្តីសម្រេចដើម្បីកំណត់ជាផ្លូវការអំពី **"តំបន់ក្រហម"**, **"តំបន់លឿងទុំ"** ឬ **"តំបន់លឿង"** នៅក្នុងភូមិសាស្ត្ររបស់ខ្លួន។*

## វិធានការអនុវត្តចំពោះ "តំបន់ក្រហម", "តំបន់លឿងទុំ" និង "តំបន់លឿង"

- ត្រូវចាប់ផ្តើមអនុវត្តចាប់ពីម៉ោងសូន្យនាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១ តទៅ។
- វិធានការដែលត្រូវអនុវត្ត គឺមានលក្ខណៈខុសគ្នារវាង "តំបន់ក្រហម", "តំបន់លឿងទុំ" និង "តំបន់លឿង"។
- ហេតុដូច្នេះ សូមប្រជាពលរដ្ឋពិនិត្យឱ្យបានច្បាស់ថា ភូមិសាស្ត្រដែលខ្លួនរស់នៅ ស្ថិតក្នុងតំបន់មួយណា។

## ទណ្ឌកម្ម
## ចំពោះការបំពានវិធានការហាមឃាត់ក្នុងអំឡុងពេលបិទខ្ទប់

បុគ្គលដែលបំពានវិធានការហាមឃាត់ការធ្វើដំណើរ និងវិធានការហាមឃាត់សកម្មភាពការងារ មុខរបរ ឬអាជីវកម្មក្នុងអំឡុងពេលបិទខ្ទប់ ត្រូវទទួលទណ្ឌកម្មពិន័យ ឬទណ្ឌកម្មព្រហ្មទណ្ឌផ្សេងទៀត ដោយរួមទាំងការឃាត់ទុកជាបណ្តោះអាសន្ននូវមធ្យោបាយធ្វើដំណើរ និងទណ្ឌកម្មរដ្ឋបាលផ្សេងទៀត ដោយអនុលោមតាមបទប្បញ្ញត្តិ និងនីតិវិធីជាធរមាន។

រៀបចំដោយ៖ ក្រសួងយុត្តិធម៌

# សេចក្តីសង្ខេបនៃវិធានការពាក់ព័ន្ធនឹងការធ្វើដំណើរចេញ-ចូល ឆ្លងកាត់ "តំបន់ក្រហម" "តំបន់លឿងទុំ" និង "តំបន់លឿង" នៃតំបន់បិទខ្ទប់

*(សេចក្តីសម្រេចលេខ ៥៤ សសរ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាល)*

## ចំណុច (ក)- ការអនុញ្ញាតឱ្យធ្វើដំណើរក្នុងចេញ-ចូល ឆ្លងកាត់ "តំបន់ក្រហម" ត្រូវបានអនុញ្ញាតដូចខាងក្រោម៖

១ ការធ្វើដំណើរដោយមូលហេតុសុខភាពបន្ទាន់

២ ការធ្វើដំណើរទៅយកសំណាក និងចាក់វ៉ាក់សាំង នៅទីតាំងជិតបំផុត ក្នុងតំបន់ក្រហម

៣ ការធ្វើដំណើររបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទដែលមានសមត្ថកិច្ចអនុវត្តវិធានការនានាក្នុងអំឡុងពេលបិទខ្ទប់

៤ ការធ្វើដំណើរដែលទាក់ទងនឹងសកម្មភាពចុះចែកជំនួយសង្គ្រោះបន្ទាន់ដែលរៀបចំដោយ គ.ប.ខ.

៥ ការធ្វើដំណើររបស់មន្ត្រីនិងបុគ្គលិកផ្នែកសុខាភិបាលទាំងរដ្ឋ និងឯកជនដោយរួមទាំងផ្នែកឱសថស្ថាន

៦ ការធ្វើដំណើររបស់មន្ត្រីនិងបុគ្គលិកនៃសេវាសង្គ្រោះបន្ទាន់ទាំងរដ្ឋ និងឯកជន

៧ ការធ្វើដំណើររបស់មន្ត្រីនិងបុគ្គលិកនៃសេវាពន្លត់អគ្គិភ័យ

៨ ការធ្វើដំណើររបស់មន្ត្រី និងបុគ្គលិកនៃសេវាផ្គត់ផ្គង់អគ្គិសនី, សេវាផ្គត់ផ្គង់ទឹកស្អាត និងសេវាផ្គត់ផ្គង់ស្បៀងរបស់រដ្ឋ

៩ ការធ្វើដំណើររបស់បុគ្គលិកនៃសេវាប្រតិបត្តិការផ្នែកទូរគមនាគមន៍

១០ ការធ្វើដំណើររបស់មន្ត្រីនិងបុគ្គលិកដើម្បីចេញ-ចូលទីតាំងឃ្លាំងស្តុកទំនិញយុទ្ធសាស្ត្ររបស់រដ្ឋ

១១ ការធ្វើដំណើររបស់បុគ្គលិកនៃទីតាំងផលិត និងផ្គត់ផ្គង់មី

១២ ការធ្វើដំណើររបស់បុគ្គលិកនៃទីតាំងផលិត និងផ្គត់ផ្គង់អាល់កុលនិងអុកស៊ីហ្សែន

១៣ ការធ្វើដំណើររបស់បុគ្គលិកលក់ និងចែកចាយហ្គាសសម្រាប់ចម្អិនអាហារ

១៤ ការធ្វើដំណើររបស់បុគ្គលិកនៃសេវាប្រមូល និងដឹកជញ្ជូនសំរាម-សំណល់រឹង

១៥ ការធ្វើដំណើររបស់បុគ្គលដែលបានបញ្ចប់ការធ្វើចត្តាឡីស័ក និងអ្នកជំងឺចេញពីមន្ទីរពេទ្យ ឬកន្លែងសម្រាកព្យាបាល ដើម្បីត្រឡប់ទៅលំនៅឋាន ឬទីសំណាក់របស់ខ្លួនវិញ

១៦ ការធ្វើដំណើររបស់អ្នកដំណើរតាមផ្លូវអាកាសទៅនិងមកពីអាកាសយានដ្ឋាន និងអាចអមដោយអ្នកបើកបរជូនដំណើរម្នាក់

១៧ ការធ្វើដំណើររបស់មន្ត្រី និងបុគ្គលិកផ្នែកប្រតិបត្តិការដែលបម្រើការងារនៅអាកាសយានដ្ឋាន

១៨ ការធ្វើដំណើររបស់មន្ត្រី និងបុគ្គលិកដែលបំពេញការងារបម្រើឱ្យការហោះហើរតាមផ្លូវអាកាស។

## ចំណុច (ខ)- ការអនុញ្ញាតឱ្យធ្វើដំណើរក្នុងចេញ-ចូល ឆ្លងកាត់ "តំបន់លឿងទុំ" ត្រូវបានអនុញ្ញាតដូចខាងក្រោម៖

១ ទៅប្រកបមុខរបរ ឬអាជីវកម្ម ឬបំពេញការងារ ដែលអនុញ្ញាតនៅក្នុង "តំបន់លឿងទុំ"

២ ការធ្វើដំណើរទៅបំពេញការងាររបស់មន្ត្រីរាជការនៃក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

៣ ការធ្វើដំណើរទៅកាន់ទីកន្លែងលក់ម្ហូបអាហារ ឬគ្រឿងឧបភោគបរិភោគ ឱសថស្ថាន និងទីកន្លែងលក់សម្ភារៈប្រើប្រាស់ចាំបាច់ប្រចាំថ្ងៃ នៅទីតាំងជិតបំផុតក្នុងរង្វង់ភូមិសាស្ត្រក្រុង ឬខណ្ឌដែលខ្លួនរស់នៅ, យ៉ាងច្រើន ២ នាក់ក្នុងមួយលំនៅឋាន ឬទីសំណាក់ និងមិនលើសពី ៣ ដងក្នុងមួយសប្តាហ៍

៤ ការធ្វើដំណើរទៅកាន់មន្ទីរពេទ្យ, មណ្ឌលសុខភាព, សម្ភព ឬទីកន្លែងព្យាបាល ដោយមូលហេតុសុខភាពបន្ទាន់

៥ ការធ្វើដំណើរទៅយកសំណាក និងចាក់វ៉ាក់សាំងនៅទីតាំងជិតបំផុត ក្នុងតំបន់លឿងទុំ

៦ ការធ្វើដំណើរទៅចូលរួមក្នុងសកម្មភាពដែលបម្រើប្រយោជន៍សាធារណៈ ឬគោលបំណងចាំបាច់ផ្សេងទៀត តាមការស្នើសុំ ឬតាមការកំណត់របស់អាជ្ញាធរអនុវត្តវិធានការបិទខ្ទប់

៧ ការធ្វើសកម្មភាពកីឡាជាលក្ខណៈបុគ្គលក្នុងរង្វង់ភូមិសាស្ត្រភូមិដែលខ្លួនរស់នៅ

៨ ការធ្វើដំណើររបស់ជនបរទេសដែលជាមន្ត្រីការទូត, មន្ត្រីបុគ្គលិកនៃស្ថានតំណាងបរទេស, ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងដែលជាមន្ត្រីរបស់អង្គការហិរញ្ញវត្ថុអន្តរជាតិ និងអាចអមដោយអ្នកបើកបរជាជនជាតិខ្មែរ

៩ ការធ្វើដំណើររបស់អ្នកសារព័ត៌មាន

១០ ការធ្វើដំណើរត្រឡប់ទៅលំនៅឋាន ឬទីសំណាក់របស់បុគ្គលដែលបានបញ្ចប់ការធ្វើចត្តាឡីស័ក និងអ្នកជំងឺចេញពីមន្ទីរពេទ្យ ឬកន្លែងសម្រាកព្យាបាល

១១ ការធ្វើដំណើរទៅបំពេញការងាររបស់កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំងមន្ត្រី និងបុគ្គលិកសុខាភិបាល

១២ ការធ្វើដំណើររបស់អ្នកដំណើរតាមផ្លូវអាកាសទៅនិងមកពីអាកាសយានដ្ឋាន និងអាចអមដោយអ្នកបើកបរជូនដំណើរម្នាក់

១៣ ការធ្វើដំណើររបស់មន្ត្រី និងបុគ្គលិកផ្នែកប្រតិបត្តិការដែលបម្រើការងារនៅអាកាសយានដ្ឋាន

១៤ ការធ្វើដំណើររបស់មន្ត្រី និងបុគ្គលិកដែលបំពេញការងារបម្រើឱ្យការហោះហើរតាមផ្លូវអាកាស។

## ចំណុច (គ)- ការអនុញ្ញាតឱ្យធ្វើដំណើរក្នុង "តំបន់លឿង"

រាល់ការធ្វើដំណើរក្នុង "តំបន់លឿង" ត្រូវបានអនុញ្ញាតឱ្យធ្វើដំណើរជាធម្មតា។

## ចំណុច (ឃ)- ការធ្វើដំណើរចេញចូលឆ្លងពីតំបន់មួយ ទៅតំបន់មួយ

១ **សម្រាប់អ្នករស់នៅក្នុង "តំបន់ក្រហម"៖** ចេញពី "តំបន់ក្រហម" ទៅ "តំបន់លឿងទុំ" និង "តំបន់លឿង" ត្រូវអនុញ្ញាតតែក្នុងករណីដែលមានក្នុងចំណុច **"ក" នៃខិត្តប័ណ្ណនេះ** លើកលែងតែការយកសំណាក និងចាក់វ៉ាក់សាំង (សូមអានចំណុច **"ក" នៃខិត្តប័ណ្ណនេះ**)

២ **សម្រាប់អ្នករស់នៅក្នុង "តំបន់លឿងទុំ"៖** ចេញពី "តំបន់លឿងទុំ" ទៅ "តំបន់ក្រហម" ត្រូវអនុញ្ញាតតែក្នុងករណីដែលមានក្នុងចំណុច **"ក" នៃខិត្តប័ណ្ណនេះ** លើកលែងតែការយកសំណាក និងចាក់វ៉ាក់សាំង (សូមអានចំណុច **"ក" នៃខិត្តប័ណ្ណនេះ**)

៣ **សម្រាប់អ្នករស់នៅក្នុង "តំបន់លឿងទុំ"៖** ចេញពី "តំបន់លឿងទុំ" ទៅ "តំបន់លឿង" ត្រូវអនុញ្ញាតតែក្នុងករណីដែលមានក្នុងចំណុច **"ក" និង "ខ" នៃខិត្តប័ណ្ណនេះ** លើកលែងតែការយកសំណាក និងចាក់វ៉ាក់សាំង (សូមអានចំណុច **"ក" និង "ខ" នៃខិត្តប័ណ្ណនេះ**)

៤ **សម្រាប់អ្នករស់នៅក្នុង "តំបន់លឿង"៖** ចេញពី "តំបន់លឿង" ទៅ "តំបន់ក្រហម" ត្រូវអនុញ្ញាតតែក្នុងករណីដែលមានក្នុងចំណុច **"ក" នៃខិត្តប័ណ្ណនេះ** លើកលែងតែការយកសំណាក និងចាក់វ៉ាក់សាំង (សូមអានចំណុច **"ក" នៃខិត្តប័ណ្ណនេះ**)

៥ **សម្រាប់អ្នករស់នៅក្នុង "តំបន់លឿង"៖** ចេញពី "តំបន់លឿង" ទៅ "តំបន់លឿងទុំ" ត្រូវអនុញ្ញាតតែក្នុងករណីដែលមានក្នុងចំណុច **"ខ" នៃខិត្តប័ណ្ណនេះ** លើកលែងតែការយកសំណាក, ការចាក់វ៉ាក់សាំង និងការធ្វើសកម្មភាពកីឡា (សូមអានចំណុច **"ខ" នៃខិត្តប័ណ្ណនេះ**)

## ចំណុច (ង)- ការធ្វើដំណើរចេញ-ចូល និងឆ្លងកាត់ភូមិសាស្ត្របិទខ្ទប់នៃរាជធានីភ្នំពេញ និងក្រុងតាខ្មៅ (ពីបណ្តាខេត្ត)

**ត្រូវបានអនុញ្ញាតតែក្នុងករណីដែលមានក្នុងប្រការ ៦ នៃសេចក្តីសម្រេចលេខ ៥៤ សសរ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១**

រៀបចំដោយ ៖ ក្រសួងយុត្តិធម៌

# វិធានការហាមឃាត់ការធ្វើដំណើរចេញ-ចូល និងឆ្លងកាត់ "តំបន់ក្រហម"

*(សេចក្តីសម្រេចលេខ ៥៤ សសរ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាល)*

## ហាមឃាត់ដាច់ខាតរាល់ការធ្វើដំណើរចេញក្រៅពីលំនៅឋាន ឬទីសំណាក់បច្ចុប្បន្ន ឬចេញ-ចូល និងឆ្លងកាត់ "តំបន់ក្រហម" លើកលែងករណីដូចខាងក្រោម៖

១. ការធ្វើដំណើរដោយមូលហេតុសុខភាពបន្ទាន់

២. ការធ្វើដំណើរទៅជួបមន្ត្រីសុខាភិបាល ដើម្បីយកសំណាកទៅវិភាគរកមេរោគកូវីដ-១៩ ឬចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ នៅទីតាំងជិតបំផុតក្នុង "តំបន់ក្រហម"

៣. ការធ្វើដំណើររបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលមានសមត្ថកិច្ចអនុវត្តវិធានការនានាក្នុងអំឡុងពេលបិទខ្ទប់

៤. ការធ្វើដំណើរទាក់ទងនឹងសកម្មភាពចុះចែកជំនួយសង្គ្រោះបន្ទាន់ដែលរៀបចំដោយ គ.ប.ខ.

៥. ការធ្វើដំណើររបស់មន្ត្រីនិងបុគ្គលិកផ្នែកសុខាភិបាលទាំងរដ្ឋ និងឯកជនដោយរួមទាំងផ្នែកឱសថស្ថាន *(ត្រូវមានលិខិតអនុញ្ញាតចេញដោយក្រសួងសុខាភិបាល)*

៦. ការធ្វើដំណើររបស់មន្ត្រីនិងបុគ្គលិកនៃសេវាសង្គ្រោះបន្ទាន់ទាំងរដ្ឋ និងឯកជន *(ត្រូវមានលិខិតអនុញ្ញាតចេញដោយក្រសួងសុខាភិបាល)*

៧. ការធ្វើដំណើររបស់មន្ត្រីនិងបុគ្គលិកនៃសេវាពន្លត់អគ្គិភ័យ

៨. ការធ្វើដំណើររបស់មន្ត្រីនិងបុគ្គលិកនៃសេវាផ្គត់ផ្គង់អគ្គិសនី, សេវាផ្គត់ផ្គង់ទឹកស្អាត និងសេវាផ្គត់ផ្គង់ស្បៀងរបស់រដ្ឋ

៩. ការធ្វើដំណើររបស់មន្ត្រីឬបុគ្គលិកនៃសេវាប្រតិបត្តិការផ្នែកទូរគមនាគមន៍

១០.ការធ្វើដំណើររបស់មន្ត្រីនិងបុគ្គលិកដើម្បីចេញ-ចូលទីតាំងឃ្លាំងស្តុកទំនិញយុទ្ធសាស្ត្ររបស់រដ្ឋ

១១.ការធ្វើដំណើររបស់បុគ្គលិកនៃទីតាំងផលិតនិងផ្គត់ផ្គង់មី

១២.ការធ្វើដំណើររបស់បុគ្គលិកនៃទីតាំងផលិតនិងផ្គត់ផ្គង់អាល់កុល និងអុកស៊ីហ្សែន

១៣.ការធ្វើដំណើររបស់បុគ្គលិកលក់ និងចែកចាយហ្គាសសម្រាប់ចម្អិនអាហារ

១៤.ការធ្វើដំណើររបស់បុគ្គលិកនៃសេវាប្រមូល និងដឹកជញ្ជូនសំរាម-សំណល់រឹង

១៥.ការធ្វើដំណើរដើម្បីត្រឡប់ទៅលំនៅឋាន ឬទីសំណាក់របស់ខ្លួនវិញរបស់បុគ្គលដែលបានបញ្ចប់ការធ្វើចត្តាឡីស័ក និងអ្នកជំងឺចេញពីមន្ទីរពេទ្យ ឬកន្លែងសម្រាកព្យាបាល នៅក្នុង ឬចេញពី ឬចូលក្នុង "តំបន់ក្រហម"

១៦.ការធ្វើដំណើររបស់អ្នកដំណើរតាមផ្លូវអាកាសទៅនិងមកពីអាកាសយានដ្ឋាន និងអាចអមដោយអ្នកបើកបរជូនដំណើរម្នាក់ *(ត្រូវមានឯកសារពាក់ព័ន្ធនឹងការធ្វើដំណើរ)*

១៧.ការធ្វើដំណើររបស់មន្ត្រីនិងបុគ្គលិកផ្នែកប្រតិបត្តិការដែលបម្រើការងារនៅអាកាសយានដ្ឋាន

១៨.ការធ្វើដំណើររបស់មន្ត្រីនិងបុគ្គលិកដែលបំពេញការងារបម្រើឱ្យការហោះហើរតាមផ្លូវអាកាស។

## ឯកសារសម្រាប់ការធ្វើដំណើរ ដែលត្រូវបានអនុញ្ញាត

### សម្រាប់មន្ត្រីសាធារណៈ

១. ឯកសារបញ្ជាក់អត្តសញ្ញាណ

២. លិខិតបញ្ជាបេសកកម្ម

### សម្រាប់អ្នកត្រូវយកសំណាក និងចាក់វ៉ាក់សាំង

១. ឯកសារបញ្ជាក់អត្តសញ្ញាណ

២. ប័ណ្ណចាក់វ៉ាក់សាំងលើកទី១ (សម្រាប់អ្នកចាក់ដូសទី២)

### សម្រាប់បុគ្គលិកនៃវិស័យឯកជន

១. ឯកសារបញ្ជាក់អត្តសញ្ញាណ

២. លិខិតអនុញ្ញាតធ្វើដំណើរចេញដោយគណៈកម្មការប្រតិបត្តិនៃ គ.ប.ខ.

៣. លិខិតបញ្ជាក់ការងារ ចេញដោយកន្លែងអាជីវកម្មពាក់ព័ន្ធ ដោយបញ្ជាក់អំពីឈ្មោះ មុខងារ និងប្រភេទអាជីវកម្ម

រៀបចំដោយ៖ ក្រសួងយុត្តិធម៌

# វិធានការហាមឃាត់ការធ្វើសកម្មភាពការងារ មុខរបរ និងអាជីវកម្ម ក្នុង "តំបន់ក្រហម"

*(សេចក្តីសម្រេចលេខ ៥៤ សសរ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាល)*

**ផ្សារ និងទីកន្លែងលក់ម្ហូបអាហារនិងគ្រឿងឧបភោគបរិភោគ និងទីកន្លែងលក់ និងសេពគ្រឿងស្រវឹងគ្រប់ប្រភេទ ព្រមទាំងសកម្មភាពការងារ មុខរបរ និងអាជីវកម្មទាំងអស់នៅក្នុង "តំបន់ក្រហម" ត្រូវបិទផ្អាកជាបណ្តោះអាសន្ន លើកលែងតែករណីដូចខាងក្រោម៖**

១. សេវាពន្លត់អគ្គិភ័យ
២. សេវាផ្គត់ផ្គង់អគ្គិសនី
៣. សេវាផ្គត់ផ្គង់ទឹកស្អាត
៤. សេវាប្រតិបត្តិការផ្នែកទូរគមនាគមន៍
៥. សេវាសង្គ្រោះបន្ទាន់ និងសេវាសុខាភិបាលទាំងរដ្ឋនិងឯកជន ដោយរួមទាំងឱសថស្ថាន
៦. ទីតាំងផលិតនិងផ្គត់ផ្គង់អាល់កុល និងអុកស៊ីហ្សែន
៧. ទីតាំងផលិតនិងផ្គត់ផ្គង់មី
៨. ទីតាំងលក់ហ្គាសសម្រាប់ចម្អិនអាហារ
៩. សេវាផ្គត់ផ្គង់ស្បៀងរដ្ឋ ឬសម្របសម្រួលដោយរដ្ឋ និងជំនួយសង្គ្រោះបន្ទាន់
១០. សេវាផ្គត់ផ្គង់ឱសថ និងសម្ភារៈបរិក្ខាពេទ្យ
១១. សេវាប្រមូល និងដឹកជញ្ជូនសំរាម-សំណល់រឹង និង
១២. អាកាសយានដ្ឋាន និងទីតាំងការងារបម្រើឱ្យការហោះហើរតាមផ្លូវអាកាស។

**រាល់ការជួបជុំ ឬការប្រមូលផ្តុំមនុស្ស ដើម្បីសេពគ្រឿងស្រវឹងគ្រប់ប្រភេទត្រូវបានហាមឃាត់!!!**

រៀបចំដោយ៖ ក្រសួងយុត្តិធម៌

# វិធានការហាមឃាត់ការធ្វើដំណើរចេញ-ចូល និងឆ្លងកាត់ "តំបន់លឿងទុំ"

*(សេចក្តីសម្រេចលេខ ៥៤ សសរ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាល)*

## ហាមឃាត់ដាច់ខាតរាល់ការធ្វើដំណើរចេញក្រៅលំនៅឋាន ឬទីសំណាក់បច្ចុប្បន្ន ឬចេញ-ចូល និងឆ្លងកាត់ "តំបន់លឿងទុំ" លើកលែងករណីដូចខាងក្រោម៖

១. ការធ្វើដំណើរទៅបំពេញការងារ មុខរបរ ឬអាជីវកម្ម ដែលត្រូវបានអនុញ្ញាតឱ្យបើកដំណើរការក្នុង "តំបន់លឿងទុំ"

២. ការធ្វើដំណើរទៅបំពេញការងារក្នុងក្រសួងស្ថាប័ន

៣. ការធ្វើដំណើរទៅកាន់ទីកន្លែងលក់ម្ហូបអាហារ ឬគ្រឿងឧបភោគបរិភោគ ឱសថស្ថាន និងទីកន្លែងលក់សម្ភារៈប្រើប្រាស់ចាំបាច់ប្រចាំថ្ងៃនៅទីតាំងជិតបំផុតក្នុងរង្វង់ភូមិសាស្រ្តក្រុង ឬខណ្ឌដែលខ្លួនរស់នៅ *(៣ ដងក្នុងមួយសប្តាហ៍)*

៤. ការធ្វើដំណើរទៅកាន់មន្ទីរពេទ្យ, មណ្ឌលសុខភាព, សម្ភព ឬទីកន្លែងព្យាបាល ដោយមូលហេតុសុខភាពបន្ទាន់នៅក្នុងរង្វង់ភូមិសាស្រ្តដែលត្រូវបានបិទខ្ទប់ ឬចេញក្រៅឬចូលក្នុងរង្វង់ភូមិសាស្រ្តដែលត្រូវបានបិទខ្ទប់ *(ត្រូវមានការអនុញ្ញាតពីអាជ្ញាធរអនុវត្តវិធានការបិទខ្ទប់)*

៥. ការធ្វើដំណើរទៅជួបមន្ត្រីសុខាភិបាល ដើម្បីយកសំណាកទៅវិភាគរកមេរោគកូវីដ-១៩ ឬចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ នៅទីតាំងជិតបំផុតក្នុង "តំបន់លឿងទុំ"

៦. ការធ្វើដំណើរទៅចូលរួមក្នុងសកម្មភាពដែលបម្រើប្រយោជន៍សាធារណៈ ឬគោលបំណងចាំបាច់ផ្សេងទៀត តាមការស្នើសុំ ឬតាមការកំណត់របស់អាជ្ញាធរអនុវត្តវិធានការបិទខ្ទប់

៧. ការធ្វើសកម្មភាពកីឡាជាលក្ខណៈបុគ្គលក្នុងរង្វង់ភូមិសាស្រ្តភូមិដែលខ្លួនរស់នៅ *(ជៀសវាងលើសពី ២ នាក់)*

៨. ការធ្វើដំណើររបស់ជនបរទេសដែលជាមន្ត្រីការទូត, មន្ត្រីបុគ្គលិកនៃស្ថានតំណាងបរទេស, ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងដែលជាមន្ត្រីរបស់អង្គការហិរញ្ញវត្ថុអន្តរជាតិ និងអាចអមដោយអ្នកបើកបរជាជនជាតិខ្មែរ

៩. ការធ្វើដំណើររបស់អ្នកសារព័ត៌មាន *(លិខិតអនុញ្ញាតសម្រាប់ការធ្វើដំណើរពីក្រសួងព័ត៌មាន)*

១០.ការធ្វើដំណើរត្រឡប់ទៅលំនៅឋាន ឬទីសំណាក់របស់បុគ្គលដែលបានបញ្ចប់ការធ្វើចត្តាឡីស័ក និងអ្នកជំងឺចេញពីមន្ទីរពេទ្យ ឬកន្លែងសម្រាកព្យាបាល នៅក្នុងឬចេញពីឬចូលក្នុង "តំបន់លឿងទុំ"

១១.ការធ្វើដំណើររបស់អ្នកដំណើរតាមផ្លូវអាកាសទៅនិងមកពីអាកាសយានដ្ឋាន និងអាចអមដោយអ្នកបើកបរជូនដំណើរម្នាក់ *(ត្រូវមានឯកសារពាក់ព័ន្ធនឹងការធ្វើដំណើរ)*

១២.ការធ្វើដំណើររបស់មន្ត្រី និងបុគ្គលិកផ្នែកប្រតិបត្តិការដែលបម្រើការងារនៅអាកាសយានដ្ឋាន

១៣.ការធ្វើដំណើររបស់មន្ត្រី និងបុគ្គលិកដែលបំពេញការងារបម្រើឱ្យការហោះហើរតាមផ្លូវអាកាស។

## ឯកសារសម្រាប់ការធ្វើដំណើរ ដែលត្រូវបានអនុញ្ញាត

### សម្រាប់មន្ត្រីសាធារណៈ

១. ឯកសារបញ្ជាក់អត្តសញ្ញាណ

២. លិខិតបញ្ជាបេសកកម្ម

### សម្រាប់អ្នកត្រូវយកសំណាក និងចាក់វ៉ាក់សាំង

១. ឯកសារបញ្ជាក់អត្តសញ្ញាណ

២. ប័ណ្ណចាក់វ៉ាក់សាំងលើកទី១ (សម្រាប់អ្នកចាក់ដូសទី២)

### សម្រាប់បុគ្គលិកនៃវិស័យឯកជន

១. ឯកសារបញ្ជាក់អត្តសញ្ញាណ

២. លិខិតអនុញ្ញាតធ្វើដំណើរចេញដោយគណៈកម្មការប្រតិបត្តិនៃ គ.ប.ខ.

៣. លិខិតបញ្ជាក់ការងារ ចេញដោយកន្លែងអាជីវកម្មពាក់ព័ន្ធ ដោយបញ្ជាក់អំពីឈ្មោះ មុខងារ និងប្រភេទអាជីវកម្ម

រៀបចំដោយ ៖ ក្រសួងយុត្តិធម៌

# សកម្មភាពការងារ មុខរបរ និងអាជីវកម្ម ដែលត្រូវអនុញ្ញាតឱ្យបើកដំណើរការ ក្នុង "តំបន់លឿងទុំ" ដោយមិនតម្រូវឱ្យកាត់បន្ថយចំនួនអ្នកធ្វើការ

*(សេចក្ដីសម្រេចលេខ ៥៤ សសរ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាល)*

## សកម្មភាពការងារ មុខរបរ និងអាជីវកម្ម ដែលមិនមែនជាតម្រូវការចាំបាច់ ត្រូវផ្អាកដំណើរការជាបណ្ដោះអាសន្ន លើកលែងតែករណីដូចខាងក្រោម៖

១. រោងចក្រ សហគ្រាស សិប្បកម្ម ឬទីកន្លែងផលិតឱសថ និងសម្ភារៈបរិក្ខាពេទ្យ រួមទាំងម៉ាស អាល់កុល និងអុកស៊ីហ្សែន

២. រោងចក្រ សហគ្រាស សិប្បកម្ម ឬទីកន្លែងផលិតម្ហូបអាហារនិងគ្រឿងឧបភោគបរិភោគ

៣. ទីសត្តឃាត

៤. សេវាពន្លត់អគ្គិភ័យ និងសេវាប្រមូល និងដឹកជញ្ជូនសំរាម-សំណល់រឹង

៥. ផ្សារលក់ដុំ និងផ្សារឬទីតាំងលក់ដូរគ្រឿងឧបភោគបរិភោគដែលមានសណ្ដាប់ធ្នាប់

៦. សេវាសង្គ្រោះបន្ទាន់ សេវាសុខាភិបាល ទាំងរដ្ឋ និងឯកជន និងឱសថស្ថាន

៧. ស្ថានីយ៍ប្រេងឥន្ធនៈ-ហ្គាស និងទីតាំងលក់ហ្គាស

៨. សេវាកម្មដឹកជញ្ជូនម្ហូបអាហារ ឬគ្រឿងឧបភោគបរិភោគ ដើម្បីបម្រើឱ្យភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ (មិនត្រូវដឹកជញ្ជូនមនុស្សឡើយ)

៩. ការដឹកជញ្ជូនទំនិញយុទ្ធសាស្ត្ររបស់រដ្ឋ

១០. សេវាកម្មដឹកជញ្ជូនទំនិញទូទៅចេញ-ចូល ឬឆ្លងកាត់ភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ ដើម្បីបម្រើឱ្យវិស័យសង្គម-សេដ្ឋកិច្ច (មិនត្រូវដឹកជញ្ជូនមនុស្សឡើយ)

១១. អាកាសយានដ្ឋាន និងទីតាំងការងារបម្រើឱ្យការហោះហើរតាមផ្លូវអាកាស។

រៀបចំដោយ ៖ ក្រសួងយុត្តិធម៌

# សកម្មភាពការងារ មុខរបរ និងអាជីវកម្ម ដែលត្រូវអនុញ្ញាតឱ្យបើកដំណើរការ ក្នុង "តំបន់លឿងទុំ" ដោយតម្រូវឱ្យកាត់បន្ថយចំនួនអ្នកធ្វើការ

*(សេចក្ដីសម្រេចលេខ ៥៤ សសរ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាល)*

## សកម្មភាពការងារ មុខរបរ ឬអាជីវកម្ម ដែលត្រូវកាត់បន្ថយចំនួនបុគ្គលិកការិយាល័យឱ្យមកត្រឹម ២% និងត្រូវហូបអាហារថ្ងៃត្រង់នៅកន្លែងធ្វើការ

១. សកម្មភាពការងាររបស់ស្ថាប័នសាធារណៈ
២. សេវាផ្គត់ផ្គង់អគ្គិសនី, សេវាទឹកស្អាត និងសេវាកំពង់ផែ (លើកលែងចំពោះមន្ត្រី ឬបុគ្គលិកទទួលបន្ទុកខាងផ្នែកប្រតិបត្តិការ និងសង្វាក់ផលិតកម្ម ដែលអាចបំពេញការងារជាធម្មតា)
៣. រាល់សកម្មភាពការងារ មុខរបរ ឬអាជីវកម្ម ដែលដំណើរការតាមរយៈប្រព័ន្ធអនឡាញ
៤. សេវាប្រៃសណីយ៍-ទូរគមនាគមន៍
៥. សេវាធនាគារ និងហិរញ្ញវត្ថុ
៦. សេវាកម្មសណ្ឋាគារ និងផ្ទះសំណាក់ (ត្រូវស្នាក់នៅកន្លែងធ្វើការ)។

## សកម្មភាពការងារ មុខរបរ ឬអាជីវកម្ម ដែលត្រូវកាត់បន្ថយចំនួនអ្នកធ្វើការត្រឹមកម្រិតអប្បបរមា តាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច និងត្រូវហូបអាហារនៅហ្នឹងកន្លែង

១. សកម្មភាពការងាររបស់កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងរដ្ឋបាលថ្នាក់ក្រោមជាតិ (ត្រូវដំណើរការស្របតាមការចាំបាច់ និងតាមការកំណត់របស់ប្រធានស្ថាប័ននីមួយ)
២. ផ្សារម៉ាត និងភោជនីយដ្ឋាន-អាហារដ្ឋានដែលលក់ជាអាហារវេចខ្ចប់
៣. សេវាកម្មសណ្ឋាគារដែលបម្រើឱ្យការធ្វើចត្តាឡីស័ក (ពេលម៉ោងធ្វើការត្រូវកំណត់ដោយអាជ្ញាធរអនុវត្តវិធានការបិទខ្ទប់)
៤. ការគ្រប់គ្រង និងថែរក្សាឃ្លាំងស្តុកទំនិញ ឬគ្រឿងឧបភោគបរិភោគ (ស្នាក់នៅនៅហ្នឹងកន្លែងធ្វើការ)។

រៀបចំដោយ៖ ក្រសួងយុត្តិធម៌

# វិធានការអនុវត្តសម្រាប់តំបន់បិទខ្ទប់ដែលជា "តំបន់លឿង"

*(សេចក្តីសម្រេចលេខ ៥៤ សសរ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាល)*

## សកម្មភាពការងារ មុខរបរ និងអាជីវកម្មគ្រប់ប្រភេទនៅក្នុង "តំបន់លឿង" ត្រូវបានអនុញ្ញាតឱ្យបើកដំណើរការជាធម្មតា លើកលែងតែករណីដូចខាងក្រោម៖

១. សាលារៀនរួមទាំងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈទាំងរដ្ឋ និងឯកជន

២. អាជីវកម្មក្លឹបកម្សាន្តគ្រប់ប្រភេទ ជាអាទិ៍ ខារ៉ាអូខេ, រង្គសាល, ឌីស្កូតែក និងបៀហ្គាឌិន

៣. រមណីយដ្ឋាន និងសួនកម្សាន្តនានា

៤. អាជីវកម្មម៉ាស្សា

៥. ហាងលក់និងសេពគ្រឿងស្រវឹងគ្រប់ប្រភេទ

៦. រោងភាពយន្ត និងរោងសម្តែងសិល្បៈ

៧. សារមន្ទីរ និង

៨. ក្លឹបហាត់ប្រាណ និងមជ្ឈមណ្ឌលកីឡា

៩. អាជ្ញាធរមានសិទ្ធិហាមឃាត់សកម្មភាពការងារ មុខរបរ និងអាជីវកម្មផ្សេងទៀត តាមការចាំបាច់។

***កំណត់សម្គាល់៖*** *សកម្មភាពការងារ មុខរបរ និងអាជីវកម្ម ដែលបើកដំណើរការនៅក្នុង "តំបន់លឿង" ត្រូវអនុវត្តវិធានការសុវត្ថិភាពផ្នែកសុខាភិបាលឱ្យបានម៉ឺងម៉ាត់ជាអាទិ៍ កាតព្វកិច្ចពាក់ម៉ាស និងកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាពបុគ្គល និងត្រូវប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេរោគ ការវាស់កម្តៅ និងការអនុវត្តវិធានការសុវត្ថិភាពផ្នែកសុខាភិបាលផ្សេងទៀត។*

## ការធ្វើដំណើររបស់ប្រជាពលរដ្ឋនៅក្នុង "តំបន់លឿង"

- ការធ្វើដំណើរគ្រប់ប្រភេទក្នុងតំបន់លឿងត្រូវបានអនុញ្ញាតឱ្យប្រព្រឹត្តទៅជាធម្មតា។
- ការធ្វើដំណើរចេញពី "តំបន់លឿង" ទៅ "តំបន់លឿងទុំ" អាចធ្វើទៅបានតែក្នុងករណីការធ្វើដំណើរសម្រាប់គោលបំណងដែលត្រូវបានអនុញ្ញាតក្នុង "តំបន់លឿងទុំ"។
- ការធ្វើដំណើរចេញពី "តំបន់លឿង" ទៅ "តំបន់ក្រហម" អាចធ្វើទៅបានតែក្នុងករណីការធ្វើដំណើរសម្រាប់គោលបំណងដែលត្រូវបានអនុញ្ញាតក្នុង "តំបន់ក្រហម"។

## ការជួបជុំ ឬការប្រមូលផ្តុំមនុស្សក្នុង "តំបន់លឿង"

- ការជួបជុំ ឬការប្រមូលផ្តុំមនុស្សជាលក្ខណៈឯកជន ដែលមានមនុស្សចូលរួមក្រោម **១០ នាក់** ត្រូវបានអនុញ្ញាត (ហាមឃាត់ការជួបជុំ ឬការប្រមូលផ្តុំមនុស្សជាលក្ខណៈឯកជន ដែលមានលក្ខណៈកុះករកកកុញ ឬមានមនុស្សចូលរួមលើសពី **១០ នាក់**)។
- **រាល់ការជួបជុំ ឬការប្រមូលផ្តុំមនុស្ស ដើម្បីសេពគ្រឿងស្រវឹងគ្រប់ប្រភេទត្រូវបានហាមឃាត់។**

## ត្រូវអនុវត្តបម្រាមគោចរក្នុង "តំបន់លឿង" ចាប់ពីម៉ោង ២០ ដល់ម៉ោង ៥

**រៀបចំដោយ ៖ ក្រសួងយុត្តិធម៌**

# បម្រាមគោចរក្នុង "តំបន់លឿងទុំ" និង "តំបន់លឿង"

*(សេចក្តីសម្រេចលេខ ៥៤ សសរ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាល)*

## រាល់ការធ្វើដំណើរ និងសកម្មភាពការងារ មុខរបរ និងអាជីវកម្ម ទាំងអស់ នៅក្នុង "តំបន់លឿងទុំ" និង "តំបន់លឿង" ត្រូវបផ្អាកជាបណ្តោះអាសន្ន

## នៅចន្លោះម៉ោង ២០ ដល់ម៉ោង ៥

## លើកលែងតែក្នុងករណីដូចខាងក្រោម៖

១. ការធ្វើដំណើររបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទដែលមានសមត្ថកិច្ចអនុវត្តវិធានការនានាក្នុងអំឡុងពេលបិទខ្ទប់

២. ការធ្វើដំណើរដោយមូលហេតុសុខភាពបន្ទាន់

៣. ការធ្វើដំណើរដោយមូលហេតុចាំបាច់និងបន្ទាន់ក្នុងគ្រួសារ

៤. ការដឹកជញ្ជូនទំនិញ

៥. ការដឹកជញ្ជូនទំនិញយុទ្ធសាស្ត្ររបស់រដ្ឋ

៦. ទីតាំងផលិតនិងផ្គត់ផ្គង់អាល់កុល និងអុកស៊ីហ្សែន

៧. ទីតាំងផលិតនិងផ្គត់ផ្គង់មី

៨. ការបំពេញកាតព្វកិច្ចដែលបម្រើផលប្រយោជន៍សាធារណៈ

៩. សេវាសង្គ្រោះបន្ទាន់ និងសេវាសុខាភិបាលទាំងរដ្ឋ និងឯកជន

១០. ឱសថស្ថាន

១១. សេវាពន្លត់អគ្គិភ័យ

១២. សេវាផ្គត់ផ្គង់អគ្គិសនី និងទឹកស្អាត

១៣. ស្ថានីយ៍ប្រេងឥន្ធនៈ-ហ្គាស

១៤. សេវាសណ្ឋាគារ និងផ្ទះសំណាក់

១៥. ករណីចាំបាច់ និងសេវាសាធារណៈចាំបាច់ដទៃទៀត ដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច

១៦. អាកាសយានដ្ឋាន និងការធ្វើដំណើររបស់អ្នកដំណើរតាមផ្លូវអាកាសទៅអាកាសយានដ្ឋាន។

រៀបចំដោយ ៖ ក្រសួងយុត្តិធម៌

# វិធានការនៃការធ្វើដំណើរចេញ-ចូល និងឆ្លងកាត់ភូមិសាស្ត្របិទខ្ទប់ នៃរាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្ដាល

*(សេចក្ដីសម្រេចលេខ ៥៤ សសរ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាល)*

## ការធ្វើដំណើរចេញ-ចូល និងឆ្លងកាត់ភូមិសាស្ត្របិទខ្ទប់នៃរាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្ដាល ត្រូវបានអនុញ្ញាតក្នុងករណី ដូចខាងក្រោម៖

១. ការដឹកជញ្ជូនម្ហូបអាហារឬគ្រឿងឧបភោគបរិភោគ ដើម្បីបម្រើឱ្យភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ *(មិនត្រូវដឹកជញ្ជូនមនុស្ស)*

២. ការដឹកជញ្ជូនទំនិញទូទៅចេញ-ចូល ឬឆ្លងកាត់ភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ ដើម្បីបម្រើឱ្យវិស័យសេដ្ឋកិច្ច-សង្គមកិច្ច *(មិនត្រូវដឹកជញ្ជូនមនុស្ស)*

៣. ការធ្វើដំណើររបស់មន្ត្រីរាជការសាធារណៈទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងគោលដៅបំពេញការងារប្រចាំថ្ងៃ *(ត្រូវមានប័ណ្ណសម្គាល់ការងារ លិខិតបញ្ជាបេសកកម្ម ឬឯកសារពាក់ព័ន្ធផ្សេងទៀត)*

៤. ការធ្វើដំណើររបស់ពលរដ្ឋទៅកាន់មន្ទីរពេទ្យ ឬមណ្ឌលសុខភាព ដែលនៅជិតបំផុត ដើម្បីទទួលបាននូវសេវាសុខភាពចាំបាច់និងបន្ទាន់ ដោយកំណត់ចំនួនមនុស្សមិនលើសពី ៤ នាក់ សម្រាប់ករណីនីមួយៗ

៥. ការធ្វើដំណើររបស់មន្ត្រីនិងបុគ្គលិកនៃសេវាសង្គ្រោះបន្ទាន់ទាំងរដ្ឋ និងឯកជន

៦. ការធ្វើដំណើររបស់មន្ត្រីនិងបុគ្គលិកនៃសេវាពន្លត់អគ្គិភ័យ

៧. ការធ្វើដំណើររបស់មន្ត្រីនិងបុគ្គលិកនៃសេវាផ្គត់ផ្គង់អគ្គិសនី, សេវាផ្គត់ផ្គង់ទឹកស្អាត និងសេវាប្រតិបត្តិការផ្នែកទូរគមនាគមន៍ *(ត្រូវមានលិខិតបញ្ជាបេសកកម្ម ឬលិខិតអនុញ្ញាតធ្វើដំណើររបស់គណៈកម្មការប្រតិបត្តនៃ គ.ប.ខ. និងឯកសារពាក់ព័ន្ធផ្សេងទៀត)*

៨. ការធ្វើដំណើររបស់បុគ្គលិកបម្រើសេវាប្រមូល និងដឹកជញ្ជូនសំរាម-សំណល់រឹង

៩. ការដឹកជញ្ជូនកម្មករទៅកាន់ទីកន្លែងការងារនៅតាមរោងចក្រ-សហគ្រាសក្នុង "តំបន់លឿង" *(ត្រូវមានប័ណ្ណអនុញ្ញាតចេញដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ)* លើកលែងតែការដឹកជញ្ជូនកម្មករចេញពី "តំបន់ក្រហម" និង "តំបន់លឿងទុំ" ដែលត្រូវបានហាមឃាត់។

**រៀបចំដោយ ៖ ក្រសួងយុត្តិធម៌**